២៤១.

# បញ្ចអភិណ្ហប្បច្ចវេក្ខណៈ

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ព.ស. ២៥១២

២៤១.
២៦១ ថ្លៃ ៥០០

www.budinst.gov.kh www.elibraryofcambodia.org

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីស្ស៊ូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**
**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage.  This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh        www.elibraryofcambodia.org

២៤១.២៦១

# បញ្ចអភិណ្ហប្បច្ចវេក្ខណៈ

សម្ដេចព្រះរាជអយ្យកោវរបក្ររណវិទូ

## សុ ជាវស

អធិបតីពុទ្ធសាសនបណ្ឌិត្យ ទ្រង់រៀបរៀង

គណៈវដ្ឋមន្ត្រី និង សម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

បោះពុម្ពលើកទី ៦

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព. ស. ២៥១២

www.budinst.gov.kh www.elibraryofcambodia.org

# PAÑCA ABHIṆHAPPACCAVEKKHAṆA

PAR
S.A.R. SAMDECH PREAH REACH AYYAKO
VARACAKRARAṆARIDDHI
SUTHĀROT
PRESIDENT DE L'INSTITUT BOUDDHIQUE

Cette publication a reçu l'approbation
du Conseil des Ministres
et des deux chefs de secte

Sixième Edition

PHNOM-PENH
EDITIONS DE L'INSTITUT BOUDDHIQUE
1969

www.budinst.gov.kh www.elibraryofcambodia.org

# អារម្ភកថា

ព្រះពុទ្ធវចនៈ នៃសម្តេចព្រះពុទ្ធអង្គជាម្ចាស់ ដែល មានចារឹកទុកក្នុងគម្ពីរទាំងឡាយជាអនេកប្បការ តែពុទ្ធសាសនិកជនដែលកាន់ព្រះពុទ្ធសាសនា ខ្លះក៏យល់ជ្រៅ បដិបត្តិត្រឹមត្រូវតាមព្រះពុទ្ធដីកា ខ្លះក៏មិនយល់មុតសេចក្តី បានជារៀបរៀងរឿងនេះ ជាសង្ខេបបែបថ្មី ដើម្បីឲ្យងាយយល់ ។

វិរបក្ររណារិទ្ធិ

www.budinst.gov.kh www.elibraryofcambodia.org

# បញ្ចអភិណ្ហប្បច្ចវេក្ខណានីតិ

គ្រានេះ នឹងសម្ដែងក្នុងបញ្ចអភិណ្ហប្បច្ចវេក្ខណៈ តាមដែលសម្ដេចព្រះអង្គីរសៈជាម្ចាស់ ទ្រង់មានព្រះពុទ្ធតម្រាស់ប្រដៅពុទ្ធបរិសទ្យ ឲ្យហាត់ពិចារណាធម៌ ៥ ប្រការ គឺ ជរា ១ ព្យាធិ ១ មរណៈ ១ សេចក្ដីព្រាត់ប្រាស ១ កម្ម ១ ព្រោះធម៌ទាំង ៥ នេះ រមែងមានដល់ខ្លួនពិត ៗ ត្រូវតែគិតឲ្យរេះពិចារណា ។

ប្រការទី ១ មានព្រះបាលីថា ជរាធម្មោម្ហិ ជរំ អនតីតោ ប្រែថា យើងមានជរាជាធម្មតា មិនកន្លងសេចក្ដីជរាទៅបាន ។

អធិប្បាយ "ជរា" សព្ទនេះ បានសេចក្ដីថា "ប្រែក្លាយ" បើរកតែកេកកតាំងទកយឯណាក៏កើតមកហើយ

www.budinst.gov.kh www.elibraryofcambodia.org

សឹងតែមានផលជាធម្មតា មិនចាំពោះថា ដល់អាយុច្រើនទើបផលនោះឡើយ សូម្បីនៅក្នុងផ្ទៃនៃមាតា តែផ្ដួចជាតិហើយក៏សឹងមានផលជាផលបពិតប្រាកដ ដ្បិតមានពេទសម្ដែងថា "មនុស្សដែលមកចាប់បដិសន្ធិក្នុងផ្ទៃមាតា កាលដំបូង ជាកាលលៈ មានសណ្ឋានដូចប្រេង ដែលប្រោះជាប់នៅចុងរោមចាមរី ល្អិតណាស់ តូចណាស់, កាលបិតនៅជាកលលៈបាន ៧ ថ្ងៃ ក៏ដកប្រែក្លាយជា អព្វុទៈ មានសណ្ឋានក្រហមដូចទឹកលាងសាច់, កាលបិតនៅជាអព្វុទៈបាន ៧ ថ្ងៃ ក៏ដកប្រែក្លាយជាបេសិ មានសណ្ឋានដូចនំកូរ កាលបិតនៅជាបេសិបាន ៧ ថ្ងៃ ក៏ដកប្រែក្លាយជាឃនៈ មានសណ្ឋានជាដុំសាច់, កាលបិតនៅជាឃនៈបាន ៧ ថ្ងៃ ក៏ដកប្រែក្លាយជាបញ្ចសាខា មានសណ្ឋានចេញពក ៥

www.budinst.gov.kh www.elibraryofcambodia.org

គឺក្បាល ១ ដៃ ២ ជើង ២, តអំពីនោះមក ក៏រមែងមានផល ជាលំដាប់ លុះដល់ប្រសូត រហូតដល់អស់អាយុសង្ខារ" ។

ឯផលមាន ២ ហៅថា បដិច្ឆន្នផល ១ អប្បដិច្ឆន្នផល ១ ឯបដិច្ឆន្នផល គឺផលនៅបិទបាំង ជនដែលមិនដឹងធម៌ល្អិត ក៏មិនស្គាល់ថា ផល, ឯអប្បដិច្ឆន្នផល គឺផលពុំបានបាំង បិទ ព្រោះធ្វើឲ្យសក់ស្កូវ ក្នែកងឹត សាច់ជ្រីវជ្រួញ គ្របៀកហ៊ឹង ធ្មេញបាក់ មានអវយវៈទុព្វលភាពជ្រុលជ្រៅ ទោរទន់ទុរេទ់ទុកគ្រប់តិរិយាបថ មហាជនក៏ស្គាល់ប្រាកដថា ផល, គួរតែសាធុជនបេះពិចារណា កុំស្រវឹងនឹងរូបរាងកាយ ដែលសម្រាប់ឲ្យផលញាំញី ។

ប្រការទី ២ សម្ដេចព្រះមហាមុនីមោលីលោក ទ្រង់ត្រាស់ឲ្យបេះពិចារណានូវព្យាធិ ដូចមានព្រះបាលីថា

www.budinst.gov.kh www.elibraryofcambodia.org

ព្យាធិធម្មោម្ហិ ព្យាធិំ អនតីតោ ប្រែថា យើង មានព្យាធិជាធម្មតា មិនកន្លងព្យាធិទៅបាន ។

អធិប្បាយថា ព្យាធិនេះ រមែងមានគ្រប់ប្រាណ ពុំដែលមានរូបបុរសស្ត្រីឯណា មិនចំពោះថា ចេញចាក មាតុទរ ទើបមានព្យាធិនោះឡើយ តែមានជាតិហើយ សូម្បី នៅក្នុងផ្ទៃនៃមាតា ក៏សឹងមានព្យាធិមកពាល់ប៉ះ ដ្បិតមាន ទារកខ្លះដែលនៅក្នុងផ្ទៃមាតា កើតរោគខ្លួនអំពីបិតា មាន វណ្ណៈខ្មៅជុំ ៗ តាមអវយវៈ ទារកដែលមានរោគារៈដូច្នេះ រមែងលូត មិនបិតៈនៅគ្រប់ខែ, បើបានៅក្នុងគភ៌ក៏គ្មានឈឺ តែកើតមក ក៏គង់មានជម្ងឺយ៉ាងធ្ងន់ជាមិនខាន, ព្យាធិនេះ មានច្រើនយ៉ាង ច្រើនសណ្ឋាន ជាអនេកប្បការ បើមាន មកដល់រូបកាយកាលឯណា ឲ្យចាប់ពីតឈឺផ្សារទល់ទុក្ខ

www.budinst.gov.kh www.elibraryofcambodia.org

វេទនាកេសុខគ្មាន, គួរតែជនមានវិចារណញ្ញាណ គ្រាន់ចិត្តនឹងរូប ដែលមានរោគាព្យាធិមកបៀតបៀន កុំស្រវឹងវង្វេងនឹងរូបបុរស ឬ រូបស្ត្រី ។

ប្រការទី ៣ សម្តេចព្រះបរមជិនស្រីជាម្ចាស់ ទ្រង់ត្រាស់ឲ្យពុទ្ធបរិស័ទ ហាត់ពិចារណានូវសេចក្តីមរណៈ ដូចមានពាក្យព្រះបាលីថា មរណធម្មោម្හិ មរណំ អនតីតោ ប្រែថា យើងមានសេចក្តីមរណៈជាធម្មតា មិនកន្លងសេចក្តីមរណៈទៅបាន ។

អធិប្បាយថា មរណៈនេះ រមែងមានមកកាត់ជីវិតិន្ទ្រិយសត្វគ្រប់ប្រាណជាធម្មតា មិនបំពោះថា ចេញចាកមាតុទរមកកាលណា ទើបបានដល់នូវមរណៈនោះឡើយ, បើថាជាតិមានហើយ សូម្បីនៅក្នុងផ្ទៃនៃមាតា ក៏សឹងមាន

www.budinst.gov.kh www.elibraryofcambodia.org

មរណៈដែរ ឥឡូវតទារកខ្លះគ្រប់ខែ តែប្រសូតមិនរួច ព្រោះ
មរណៈក្នុងផ្ទៃ ធ្វើឲ្យមាតារន្ធត់ភ័យឈឺផ្ទៃស្ទើរក្ស័យប្រាណ
ចួនណា ឆ្មប់តែទាញយកមិនបាន តោងតែទៅរកពេទ្យ
ដែលចំណាន ឲ្យទៅជួយជាប្រញាប់ ពេទ្យក៏យកគ្រឿង
ប្រដាប់មានដង្កាប់ធំតូច និងដង្កៀបមកលូកដង្កៀបកាត់ក្បាល
ជាមុខក៏មាន ដៃ ឬ ជើងជាមុនក៏មាន តាមទំនងដែល
ស្រួលធ្វើយ៉ាងណា មានឈាមជាបដិកូល មិនគប្បីជាទី
ទស្សនាការ, ឯមាតាត្រូវដាក់ថ្នាំសន្លប់ កាលបើពេទ្យកាត់
យកសាកអសុភទារកនោះបានមកគ្រប់សព្វ មាតាត្រឡប់
ជាមានជីវិតរស់នៅតទៅសិនក៏មាន មានខ្លះពុំបានប៉ុន្មានថ្ងៃ
ស្រាប់តែក្ស័យតាមបុត្រទៅក៏មាន, មរណៈ រមែងមាន
បំផ្លាញជីវិតសត្វលោកគ្រប់វ័យ មិនថា បឋមវ័យ មជ្ឈិមវ័យ

www.budinst.gov.kh www.elibraryofcambodia.org

បច្ចិមវ័យ មិនយល់មុខថា ក្សត្រ មន្ត្រី គហបតី អ្នកមាន អ្នកក្រទៀយ តែមានជាតិហើយ ទៀវតែស្លាប់ទៅវិញជាធម្មតា, មរណៈនេះ រួមមកមាន ២ ហៅថា កាលមរណៈ១ អកាលមរណៈ១ ។ កាលមរណៈ គឺស្លាប់ឯងតាមកាល, ឯអកាលមរណៈ គឺស្លាប់ដោយគេសម្លាប់ ឬ ស្លាប់ដោយហេតុអ្វីផ្សេង ៗ មានធ្លាក់ពីលើដើមឈើ លង់ទឹក ជាដើម, ទើបមានបទលោកប្រដៅឲ្យនឹកដល់សេចក្ដីមរណៈ គ្រប់ដង្ហើមដកចេញចូលថា "យើងគង់តែដល់នូវមរណៈ, ត្រូវតែខំឧស្សាហ៍សាងកុសល ពាន់កាលជីវិតនៅ, ខ្លួនកំនៅរឹងប៉ឹង កុំស្រវឹងវង្វេងដោយមោហៈថា សត្វនៅឋិតថេរមាំមួន" ។

www.budinst.gov.kh www.elibraryofcambodia.org

ប្រការទី ៤ មានក្បួនព្រះពុទ្ធតម្រាស់ទ្រង់ត្រាស់ជាព្រះបាលីថា សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ ប្រែថា សេចក្ដីព្រាត់ប្រាសនិរាសចាកវត្ថុទាំងពួង ដែលជាទីស្រឡាញ់ ពេញចិត្ត គង់តែនឹងមានដល់យើង ។

**អធិប្បាយថា** វត្ថុទាំងពួង ដែលយើងស្រឡាញ់ពេញចិត្តនោះ មានច្រើនប្រការ គឺមាតា បិតា បុត្រ ភរិយា ញា-តិកា សាលោហិត និងវត្ថុឥតវិញ្ញាណដែលយើងគាប់ចិត្ត គឺមាស ប្រាក់ រតនាភរណៈ គេហៈ ស្រែចំការ ច្បារដំណាំ, វត្ថុទាំងអម្បាលនេះ ត្រូវតែនឹកឲ្យចាំថា គង់តែព្រាត់ប្រាសនិរាសទៅវិញ, ក៏សេចក្ដីដែលនិរាសនោះមិញ គង់តែនឹងមានដល់យើង បើថា វត្ថុនោះនៅមិនទាន់ប្រាសពីយើង

www.budinst.gov.kh www.elibraryofcambodia.org

ក៏គន់តែយើងស្ដាប់ព្រាត់ពោលវត្តនោះមិនខាន មិនដែល

បានព្រាត់ប្រាសព្រមព្រៀងគ្នា ក្នុងវេលាមួយនោះឡើយ,

បើវិញផង មាននមនសិការៈប្រាកដក្នុងចិត្តហើយ ទោះបី

វត្តឯណានិពសប្រាសព្រាត់ ក៏ពុំបានពេបមាត់ទ្រហោយំ

ននៀលប្រមៀលប្រាណ ដែលសម្ដេចព្រះដ៏ទ្រង់ញាណ

ទ្រង់ទុកថាជាអពមង្គល ដ្បិតវិញជនបានយល់ថា សេចក្ដី

ដូច្នេះនេះ គង់តែមានដល់យើង សុទ្ធសឹងតែជាសាមញ្ញ-

លក្ខណៈ(១) គួរកំណត់កត់ចំណាំ ។

ប្រការទី ៤ សម្ដេចព្រះសយម្ភូញាណ ទ្រង់មានព្រះ

ពុទ្ធត្រាស់ ដូចមានព្រះបាលីថា កម្មស្សកោម្ហិ

កម្មទាយោទា កម្មយោនិ កម្មពន្ធុ កម្មប្ប-

---

១ អនិច្ចលក្ខណៈ ទុក្ខលក្ខណៈ អនត្តលក្ខណៈ ។

www.budinst.gov.kh www.elibraryofcambodia.org

ដិសរណោ យំ កម្មំ ករិស្សាមិ កល្យាណំ វា បាបកំ វា តស្ស ទាយាទោ ភវិស្សាមិ ប្រែថា យើងមានកម្មជារបស់ខ្លួន ជាអ្នកទទួលយកនូវផលកម្ម មានកម្មជាកំណើត មានកម្មជាផៅពង្សសាច់សន្តាន មានកម្មជាគ្រឿងរឭក, បើយើងធ្វើនូវអំពើឯណា ជាបុណ្យ ឬ ជាបាប, យើងជាអ្នកទទួលយកនូវផលនៃអំពើនោះ ។

អធិប្បាយថា “កម្ម” ស័ព្ទនេះ បានសេចក្តីថា ធ្វើ, ការដែលធ្វើមាន ២ បើធ្វើល្អហៅថា កុសលកម្ម បើធ្វើអាក្រក់ហៅថា អកុសលកម្ម ដ្បិតកម្មគឺធ្វើនេះ ជាកំណើត តែកើតមក ក៏សឹងមានផលកម្មជាប់មកផងពុំមានឃ្លាតជាពូជពង្សវង្សគណាញាតិ ជាមរតក, បើថា អំពីអតីត

www.budinst.gov.kh www.elibraryofcambodia.org

ខ្លួនប្រព្រឹត្តល្អ ឬ អាក្រក់ ដែលកើតមកនេះ ក៏សឹងតែទទួលនូវមរតកនោះពុំមានខាន បើថា ក្នុងបច្ចុប្បន្នជាតិនេះបានធ្វើអំពើអ្វី ជាបុណ្យ ឬ បាប ទាំងប៉ុន្មាន កាលស្លាប់អំពីជាតិនេះទៅអនាគតជាតិ ក៏មិនឃ្លាតអំពីផលកម្មដែលខ្លួនធ្វើ ៗ

តែមានបុគ្គលខ្លះយល់ជ្រុល បើខ្លួនប្រព្រឹត្តធ្វើនូវអំពើអ្វីមិនគប្បី ហើយមានគេស្តីបន្ទោស ក៏ឆ្លើយតបមកវិញឥតបង្អង់ថា “ចិត្តខ្ញុំក៏មិនចង់ដែរ តែកម្មមកនាំខ្ញុំទេ” ពាក្យនេះ បើស្តាប់ទៅឃើញហាក់ដូចជាកម្មនេះ មានខ្លួនគេតូ-កែមួយដែរ សូម្បីចិត្តមិនចង់ តែកម្មគេនាំតម្រង់ ឬ បង្វែរទៅផ្លូវណា ចិត្តក៏សឹងតែបែរប្រែទៅផ្លូវនោះ, បើប្រសិនណា កម្មនោះ ដូច្នោះពិត សម្តេចព្រះវិជិតមារសាស្តាចារ្យពុំទ្រង់ប្រដៅឲ្យពុទ្ធបរិសទ្យហាត់ធ្វើ សីល សមាធិ បញ្ញា

www.budinst.gov.kh www.elibraryofcambodia.org

ឡើយ, បើទុកជាធ្វើទៅហើយ ក៏គ្មានប្រយោជន៍អ្វីដែរ ព
ស្រេចតែកម្មគេបង្វែរប្រែទៅផ្លូវណា ។

មួយវិញទៀត បើថា កម្មនោះ ក្រៅចិត្តរបស់អាត្មា, បុរសដែលចង់បានស្ត្រីជាភរិយា មិនបាច់ទៅរកអ្នកផ្លូវចៅមហាទៅដណ្តឹងរៀបការអាពាហ៍ពិពាហ៍ នាំឲ្យខាតមាសប្រាក់ដើកករណៈឡើយ ត្រូវនៅឲ្យតែស្ងៀមយ៉ាងព្រងើយ ទុកឲ្យកម្មគេចាត់ការ ក៏គង់តែកម្មគេចាប់ផ្សំគ្នាព្រមស្រេច មិនបាច់ព្រួយ ។

សេចក្តីដែលពិត កម្មនេះ មិនមែនមានឋានមួយនៅឯណានោះឡើយ គឺចិត្តនេះហើយដែលនាំឲ្យកើតកម្ម ក៏ឯកម្មដែលជាកុសល ឬអកុសល សឹងមានឲ្យអំណោយផលច្រើនប្រការ តែក្នុងទីនេះនឹងបង្អុលផលជាសង្ខិតកថា សេចក្តីថា

បុគ្គលឯណាមានកម្មគឺធ្វើ ទោះបីធ្វើកុសលក្តី អកុសលក្តី ក្នុងបច្ចុប្បន្ន ហើយមានឲ្យអំណោយ(១) ផលក្នុងបច្ចុប្បន្ន, ផលដូច្នេះនេះ ហៅថា ទិដ្ឋធម្មវេទនីយកម្ម, បើឲ្យអំណោយផល បន្ទាប់អំពីជាតិនេះ ហៅថា ឧបបជ្ជវេទនីយកម្ម, បើថាធ្វើក្នុងបច្ចុប្បន្នជាតិនេះ តែដល់ទៅជាតិទី ៣ ឬ ច្រើនជាតិទើបឲ្យអំណោយផល ហៅថា អបរាបរវេទនីយកម្ម, រីកម្មដែលអំណោយផលមិនដូចគ្នាយ៉ាងនេះ មានបទសម្តែងថា “ព្រោះអ្នកដែលប្រព្រឹត្តកម្មនោះ មានចេតនាមិនស្មើគ្នា មានក្លា មានអន់ ។

ន័យ ១ វិញទៀត ផលកុសលកម្ម និងអកុសលកម្ម មានកាត់មុខគាក្នុងបច្ចុប្បន្នក៏មាន គឺ: ដូចមានរឿងនិទាន

---

១ អំណោយល្អបានមាសប្រាក់ អំណោយអាក្រក់បានទុក្ខទោស ។

អង្គុលិមាលៈ ដែលធ្វើមនុស្សឃាត អំណោយផលត្រូវព្រះ
បរមក្សត្រចាប់ពិឃាតប្រហារជីវិត តែអំណាចកម្មដែល
បានបព្វជ្ជាជាបព្វជិតហើយ បានទាន់សម្រេចជាព្រះអរិយៈ
ផលកម្មល្អទៅកាត់ផលអាក្រក់បានរួចខ្លួនទទេ ដូច្នេះក៏មាន
ក៏ឯផលកម្មអាក្រក់ទៅកាត់ផលល្អនោះ ដូចមានរឿងនិទាន
ព្រះបាទអជាតសត្តុពជព្រះទៅក្រុងមគធៈ បើតាមផលកម្ម
អំពីអតីតមក ទំនងឲ្យសម្រេចអរិយមគ្គក្នុងបច្ចុប្បន្ន ដែលទ្រង់
នៅក្នុងពជសម្បត្តិ តែផលកម្មអាក្រក់ទៅកាត់ឧបនិស្ស័យ
ព្រោះទ្រង់ធ្វើបិតុឃាត ឲ្យព្រះបិតាក្សយព្រះជន្ម បានជា
មានការៈ ព្រះបាលីឲ្យពិចារណាថា យើងជាអ្នកទទួលនូវ
ផលនៃអំពើនោះ គឺថា បើមិនបានទទួលអំណោយផល
ខាងល្អ ក៏គង់បានទទួលអំណោយផលខាងអាក្រក់ ឲ្យ

www.budinst.gov.kh www.elibraryofcambodia.org

ប្រែហាក់ជាខានទទេសោះនោះ ពុំមានឡើយ វៀរមួយតែព្រះអរហន្ត ដែលលោកចូលកាន់អនុបាទិសេសនិព្វានទៅហើយ ទើបពុំមានផលកម្មប្រចាំការ ហៅថា អហោសិកម្ម ។

ហេតុនេះ គួរតែពួកពុទ្ធបរិស័ទបដិបត្តិឲ្យចាំព្រះបណ្តាំ បួរហាត់ចិត្តឲ្យផុតចាកកិលេស គឺ រាគៈ ទោសៈ មោហៈ ឱស្រាហ៍លះអកុសលឲ្យដល់ព្រះនិព្វាន ឲ្យជាអហោសិកម្មដែលគ្មានផលកម្មអ្វីមកកាត់មុខ, ព្រះបរមពុទ្ធាធិប្បាយដែលទ្រង់សម្តែងទុក មុខគួរឲ្យបេះពិចារណា មិនគួរមានឧបាទានឲ្យជាប់គត បើជាប់គត គង់តែមានជាតិ ជរា ព្យាធិ មរណៈ សេចក្តីព្រាត់ប្រាស ពីព្រោះហេតុ គឺខ្លួនធ្វើ ដឿតបុថុជ្ជន ចិត្តមិនទៀង រមែងធ្វើល្អខ្លះ អាក្រក់ខ្លះ

www.budinst.gov.kh www.elibraryofcambodia.org

ជួនណាផ្លាស់ពីមនុស្សទៅទេវលោក ជួនណា ធ្លាក់ពីសុគតិទៅនិរយាបាយ ដោយផលនៃកម្ម ដ្បិតចិត្តតាំងក្នុងអាសវៈ(១) ម្ល៉ោះហើយចិត្តរំទាញញ៉ាក់ ម្ដងទៅខាងណេះ ម្ដងទៅខាងណោះ, ក៏ឯចិត្តមនុស្សនោះរសើបណាស់ ក៏កិរិយាដែលរសើបហ្នឹងមាន ២ គឺរសើបដោយគេទាក់ ១ រសើបឯង ១, រសើបដោយគេទាក់ រឿងទាំងពួងក៏សឹងតែជ្រាបគ្រប់នាក់, ឯរសើបឯង គឺចិត្តបណ្ដោយឲ្យសរសៃញ៉ាក់ ព្រោះសោយអារម្មណ៍ ដ្បិតមានបុគ្គលខ្លះឮស្គរភ្លេងតូរ្យតន្ត្រីលេងរាំ ស្រាប់តែលើកដៃរាំហើយច្រៀងផងក៏មាន ខ្លះទៅមើលល្ខោន មានតួនាងឈ្មោះអ្វីនោះត្រូវគេវាយដំច្រំដាក់ អ្នកមើលក៏ស្រាប់តែយំស្រក់ទឹកភ្នែកហូរ

---

១ កាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ ។

www.budinst.gov.kh www.elibraryofcambodia.org

សស្រាក់ផាក់មុខក្អក ក្នុងខណៈនោះ ត្រូវបទគេបេញ ក្តុកលេងកំប្លែងឲ្យសើច អ្នកដែលយំផើបមើល ក៏អស់សំណើចទាំងទឹកភ្នែកក៏មាន, មានបុគ្គលខ្លះស្តាប់គេមើលសាស្ត្រា ត្រូវរឿងនិទានទៅក្ដីនោះ ជាមនុស្សចិត្តអាក្រក់ធ្វើបាបគេឥតមានមេត្តា, អ្នកស្តាប់ស្រាប់តែខឹង ហាមាត់ជេរក៏មាន, ចិត្តដែលរសើបសឹងមានដោយប្រការដូច្នេះៗ

ហេតុនេះ គួរតែបេះធ្វើចិត្តឲ្យជាសមាធិ ដោយសមថ-ភាវនា និងវិបស្សនាភាវនា តាមដែលសម្តេចព្រះបរមគុរទ្រង់ទូន្មាន, ក៏កិរិយាដែលរសើបក្តី ឬឲ្យកាយនិងវាចាប្រព្រឹត្តកម្មជាកុសល ជាអកុសល សុចរិត ទុច្ចរិត បុណ្យ បាបក្តី ក៏មកតែអំពីចិត្តរបស់ខ្លួននាំទាញញាក់ បានជាសម្តេចព្រះដ៏ទ្រង់លក្ខណ៍ ទ្រង់ទូន្មានដូចមានព្រះបាលីថា

www.budinst.gov.kh www.elibraryofcambodia.org

សចិត្តបរិយោទបន : ប្រែថា "ឲ្យជម្រះចិត្តខ្លួនឲ្យបរិ-សុទ្ធ" បានសេចក្តីថា បើនរជាតិជនឯណា បានជម្រះចិត្តខ្លួនឲ្យបរិសុទ្ធផុតល្ងង់ គឺ មិនលោភ មិនខឹង មិនវង្វេង, ចិត្តនោះ ក៏ស្អាតនេងឥតអ្វីមកទាញទាក់ញាក់បានឡើយ ។

អធិប្បាយថា មនុស្សយើងនេះ ដែលកើតមកហើយ លុះតែរៀនហាត់ជម្រះចិត្ត កម្ចាត់នូវសេចក្តីល្ងង់ ទើបមានបញ្ញា មិនមែនដូចព្រឹក្សរុក្ខជាតិនោះឡើយ, ក៏ធម្មតារុក្ខ-ជាតិទាំងឡាយ បើដល់រដូវហើយ ក៏សឹងតែផ្កាឯងផ្លែឯង, ផ្លែណាដែលមានរសចត់ក៏ចត់ឯង ជូរក៏ជូរឯង ផ្អែមក៏ផ្អែមឯង មិនបាច់ដាក់ស្ករ ក៏ធម្មជាតិមនុស្សនេះ បើនឹងមានក្លិនក្រអូបល្អ ក៏ព្រោះតែលាបទឹកអប់ បើនឹងមានបំណេះគ្រប់សព្វ ក៏ព្រោះតែបានហាត់រៀន បើនឹងបានដល់ព្រះនិព្វាន

www.budinst.gov.kh www.elibraryofcambodia.org

ក៏ព្រោះតែព្យាយាមហាត់ចិត្តប្រព្រឹត្តត្រូវផ្លូវ(១) មិនមែននៅតែស្ងៀម ស្រាប់តែបេះដឹងបានដល់ព្រះនិព្វានឯងនោះទេ, ពួកបុថុជ្ជនទាំងឡាយ ទាំងយើងទាំងគេ ដែលនឹងឲ្យរួចចាកទុក្ខអំពីប្រាណ លុះតែបានព្យាយាមក្នុងត្រៃសិក្ខា គឺសីលសិក្ខា ចិត្តសិក្ខា បញ្ញាសិក្ខា លុះត្រាសម្រេចអរិយ-មគ្គ មានសោតាបត្តិមគ្គជាដើម ដរាបដល់អរហត្តផល ទើបបានដល់ព្រះនិព្វានផុតចាកទុក្ខ បុគ្គលដែលឆ្ពោះមុខយកទីអរិយមគ្គ សុទ្ធតែមានវិរិយៈក្រៃពេកណាស់ លុះតែសម្រេចព្រះអរហត្តជាព្រះអរហន្ត ទើបលះអស់បាបបុណ្យទាំងពួងមិនសល់ ។

តែមានខ្លះមកនឹកឆ្ងល់ថា ព្រះអរហន្តត្រូវលះតែខាង

១ ផ្លូវ ៨ គឺអដ្ឋង្គិកមគ្គ ។

www.budinst.gov.kh www.elibraryofcambodia.org

បាប ចុះហេតុអ្វីក៏មកលះខាងបុណ្យដែរ ? សេចក្ដីនេះគួរតែកុំឲ្យឆ្ងល់ ប្រៀបបីដូចបុគ្គលបរិភោគអាហារ បើបរិភោគឆ្អែតហើយកាលណា គេរមែងលែងលះឲ្យទៅក្មេងក្មាងរក់បរិភោគ គេមិនដែលឆ្អែតហើយនៅតែបៀមបាយទុលថ្កាល់ត្រកៀក ដូចជាសត្វពានរវាប់បរិភោគនោះឡើយ, ព្រះអរិយបុគ្គល ដែលលោកបានសម្រេចព្រះអរហត្តកាត់កិលេសអស់ហើយ លោកឥតមានឃ្លានប្រាថ្នាបុណ្យអ្វីឡើយ ព្រះហឫទ័យលោកស្អាតថ្លាជាឆឡង្គុបេក្ខា (១) មានតែមហាកិរិយាប្រព្រឹត្តតាមធម្មវិន័យពុទ្ធប្បញ្ញត្តិ ។

ហេតុនេះ គួរពួកពុទ្ធបរិស័ទ ហាត់ធ្វើចិត្តឲ្យស្អាតថ្លាកុំប្រកបដោយលោភចេតនា ទោះបីធ្វើការកុសលផ្លូវណាក៏

---

១ ព្រងើយមិនឃ្លៀងដោយអារម្មណ៍ទាំង ៦ ។

www.budinst.gov.kh www.elibraryofcambodia.org

កុំឲ្យជាខ្ញុំនៃតណ្ហា គឺប្រាថ្នាឥស្សរិយយសនិងភោគសម្បត្តិ ក្នុងភព, តណ្ហានេះ រាំងឃាត់ទប់មិនឲ្យដល់ទីវិមុត្តិរួចផុតទុក្ខក្នុងកាយ, លុះតែលះតណ្ហា ទើបឈ្នះទុក្ខទាំងឡាយគ្រប់ប្រការ ដូចមានព្រះបាលីសម្ដែងថា តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ ប្រែថា ធ្វើឲ្យអស់តណ្ហា ទើបឈ្នះទុក្ខទាំងពួង ។

**អធិប្បាយថា** ទុក្ខទាំងពួងដែលគ្មាន គឺមកអំពីអស់នូវតណ្ហា ឯតណ្ហាដែលអស់ មកអំពីបញ្ញាប្រហារ, ដែលធ្វើឲ្យកើតបញ្ញា មកអំពីការនៃជាសមាធិ, ដែលធ្វើឲ្យកើតសមាធិមកអំពីជាប់សីលជាដើម សីលនេះ ជាមេផ្ដើមដើមផ្លូវក្សាលស្ពាន ដូចមានព្រះបាលីសម្ដែងថា សីលំ សេតុ មហេសក្ខោ ប្រែថា "សីលជាស្ពានមានស័ក្ដិធំ"

គឺថាសីលនេះ ជាស្ពានសម្រាប់បុគ្គលអ្នកមានបំណងដើរឆ្លងទៅកាន់ព្រះនិព្វាន ដែលមានស័ក្តិដ៏ធំ ព្រោះសីលនេះជាមេដើមហេតុ ឲ្យកើតសមាធិបញ្ញា, លះតណ្ហាបានសម្រេចមគ្គផលដល់ព្រះនិព្វានបាន ។

តែបើពោលដោយអត្ថនោមត្យាធិប្បាយ ឃើញថាបុគ្គល ដែលមានខន្តីសន្តានគម្រើលខ្ជិល ធ្វើបានតែត្រឹមសីល ឥតព្យាយាមធ្វើឲ្យកើតសមាធិ បញ្ញា, បើដូច្នេះនេះកុំសង្ឃឹមថា នឹងលះនូវតណ្ហាបាន, ដោយហោចទៅ តែឆ្នាំងនិងបង្រ្កានកិលេះមិនដាច់ ។

ក៏ឯសីលឧបោសថ បើគេព្យាឲ្យសម្រេចផលប្រយោជន៍នោះ ឃើញមានបទសម្តែងថា លុះតែប្រកបដោយវិរិយៈ ៤ ប្រការ ។

www.budinst.gov.kh www.elibraryofcambodia.org

ប្រការទី ១ មានព្រះបាលីថា កាលេន ធម្មស្សវនំ បានសេចក្តីថា ក្នុងវេលាកាល(១) នោះត្រូវសវនាការព្រះសទ្ធម្មទេសនា ដើម្បីឲ្យមានសទ្ធាជ្រះថ្លាក្នុងព្រះបវរពុទ្ធសាសនា ស្គាល់ផ្លូវសម្មាបដិបត្តិពេញទី ។

ប្រការទី ២ កាលេន ធម្មសាកច្ឆា គឺថា ក្នុងវេលាកាលនោះ ត្រូវធម្មសាកច្ឆា ដើម្បីកម្ចាត់បង់នូវវិចិកិច្ឆា យល់ផ្លូវបញ្ញាសត្យសេចក្តី ។

ប្រការទី ៣ កាលេន សមថោ គឺថា ក្នុងវេលាកាលនោះ ត្រូវធ្វើសមថភាវនា ដើម្បីកម្ចាត់បង់នូវនីវរណៈឲ្យដល់ថ្នាក់សមាធិយ៉ាងមាំមួន ។

ប្រការទី៤ កាលេន វិបស្សនា គឺថា ក្នុងវេលា

---

១ កាលដែលបានរក្សានូវឧបោសថ បើក្រៅកាលក៏ត្រូវតែធ្វើវីរិយៈ ។

កាលនោះ ត្រូវបម្រើនវិបស្សនាការនា ដើម្បីឲ្យកើតបញ្ញា ប្រហារនូវកិលេសតណ្ហាឲ្យដាច់ ទើបសម្រេចមគ្គផល ដល់ព្រះនិព្វាន ។

ហេតុនេះ បានជាឃើញថា បើបានរក្សាឧបោសថសីល ហើយថែមមានវិរិយៈទាំង ៤ ប្រការ ទើបចាត់ថា សីលនេះ ពេញជាស្ពានបាន បើថា គ្រាន់តែតែងខ្លួនកុមផាន ហើយទៅឈរយកខ្យល់អាកាស តែត្រឹមក្បាលស្ពាន តែមិនឈានដើរឆ្លងទៅទៀត មុខជាមិនឃ្លាតទៅដល់ភូមិលោកុត្តរៈឡើយ សូម្បីបានបព្វជ្ជាជាបព្វជិតហើយ តែមិនហាត់ធ្វើចិត្តឲ្យកើតសមាធិបញ្ញា ក៏ស្មើគ្នានឹងអ្នកដែលឈរលេងនៅក្បាលស្ពាននោះដែរ ។

ឯយើងជាបុថុជ្ជន ធ្ងន់ដោយកិលេស គួរតែខំវិរិយៈ

www.budinst.gov.kh www.elibraryofcambodia.org

តាមបទដែលលោកប្រដៅ កុំឲ្យប្អូនម៉ៅផ្ដេកផ្ដួលទៅលើឧបនិស្ស័យនោះឡើយ, សូម្បីសម្ដេចព្រះដ៏មានបុណ្យជាម្ចាស់ ដែលទ្រង់មានឧបនិស្ស័យយ៉ាងក្រាស់ បានសាងព្រះបារមីមកច្រើនកប្បហើយ ដល់មកបច្ឆិមភវិកជាតិនឹងត្រាស់បរមាភិសេកសម្ពោធិញាណ សុទ្ធសឹងតែមានវីរិយៈព្យាយាមយ៉ាងក្រៃពេកណាស់, ឧបនិស្ស័យនឹងបានដើរមកអភិសេកថ្វាយឲ្យទ្រង់ត្រាស់នោះក៏ទេ, ឧបនិស្ស័យនេះប្រៀបដូចអ្នកដែលគេបរិបូណ៌ទៅដោយស្រូវពូជ ពេញជង្រុក, ក៏ឯអ្នកដែលធ្វើស្រែ បានស្រូវផ្លែពេញបន្ទុក ក៏ព្រោះតែអ្នកនោះ ខំព្យាយាមកាប់គាស់រាស់ភ្ជួរ យកស្រូវពូជដែលនៅក្នុងជង្រុកនោះទៅដាំ ទើបមានផល ដ្បិតស្រូវពូជឥតជើង ដើរទៅមិនដល់ក្នុងស្រែនោះឡើយ ។

ហេតុនេះ គួរហើយតែពួកពុទ្ធសាសនិកជន មានវិចារណញ្ញាណ មានគំនិតប្រព្រឹត្តដោយចរិយាវត្ត ឲ្យស្គាល់កុសលបច្ចុប្បន្ន កុំទម្រន់ផ្អែកទៅលើអ្វី ១ នោះឡើយ, ដែលធ្វើឲ្យទុក្ខភ័យបានស្បើយរហើយបាត់ ក៏ព្រោះតែបេះកម្ចាត់ដោយការដែលបានហាត់រៀនមានចំណេះ, ពាក្យដែលហៅថា "ចំណេះ" ជាភាសាខ្មែរៈ បើហៅជាពាក្យមគធៈថា "វិជ្ជា" បើឥតចំណេះហៅថា "អវិជ្ជា" ឯយើងរាល់គ្នាដែលកើតមកនេះ សុទ្ធតែឥតចំណេះគឺអវិជ្ជា, លុះតែបានហាត់រៀនទើបមានចំណេះគឺវិជ្ជា, វិជ្ជានេះ បើមានមែនអាចកម្ចាត់អវិជ្ជាបាន ដូចជាមនុស្សកាលនៅល្ងង់មិនទាន់ចេះ បើជា បានហាត់រៀនមានចំណេះ រមែងអាចកម្ចាត់សេចក្តីល្ងង់បាន, ឯវិជ្ជាមានច្រើនសណ្ឋាន ដែលធ្វើឲ្យ

www.budinst.gov.kh www.elibraryofcambodia.org

បម្រើនក៏មាន ឲ្យវិនាសក៏មាន ដូចមានព្រះបាលីសំដែងថា

សុវិជ្ជានោ(១) ភវំ ហោតិ ទុវិជ្ជានោ បរាភវោ

ប្រែជាសេចក្ដីថា អ្នកមានវិជ្ជាល្អ រមែងចម្រើន អ្នកមានវិជ្ជាអាក្រក់ រមែងវិនាសទៅខាងមុខ ។

អត្ថាធិប្បាយតាមបទដែលមានទុក លោកសម្ដែងថា យោគាវចរកុលបុត្រឯណា បានហាត់ប្រៀនរៀនវិជ្ជា ញុំាងកាយសុចរិត វចីសុចរិត មនោសុចរិត ឲ្យឋិតនៅក្នុង

---

១-២- បាលីក្នុងបរាភវសូត្រនេះថា “ សុវិជានោ ” ដូចគ្នាទាំងពីរបទ, ពុំមែនថា “ សុវិជ្ជានោ-ទុវិជ្ជានោ ” តាមដែលធ្លាប់ប្រឡមកយូរហើយដូច្នេះទេ គឺសំដៅសេចក្ដីថា “ សេចក្ដីចម្រើន គប្បីគេអាចដឹងដោយងាយ, សេចក្ដីវិនាស ក៏គប្បីគេអាចដឹងដោយងាយដែរ ” ពុំមែនសំដៅសេចក្ដីថា “ វិជ្ជាល្អ និងវិជ្ជាអាក្រក់ ” ដូចក្នុងទីនេះឡើយ ។ ចូរមើលអដ្ឋកថា នៃសូត្រនេះ ។ ក្រុមជំនុំព្រះត្រៃបិដក ។

www.budinst.gov.kh www.elibraryofcambodia.org

ហេតុនេះ គួរតែពួកពុទ្ធមាមកៈ ដែលជាអ្នកកាន់តាមព្រះពុទ្ធជាម្ចាស់ ចូររៀនតែវិជ្ជាខាងល្អ កុំរៀនវិជ្ជាខាងកាក្រក់ ឲ្យហក់មកប៉ះ, ត្រូវតែរៀនវិជ្ជាតាមព្រះបរមពុទ្ធតម្រាស់ បើមិនយល់ ត្រូវតែសិក្សាឲ្យច្បាស់ ដ្បិតវិជ្ជាល្អក្នុងលោក រៀនឲ្យដុំកពពក់មិនបប់ផុត ។

មានរឿងនិទានថា ព្រះសារីបុត្តអគ្គសាវក កាលគ្រាពុទ្ធសម័យ សម្តេចព្រះចបព្រៃ ទ្រង់លើកជាឯតទគ្គៈខាងបញ្ញាក្នុងជាន់នោះ, ដូចជាគ្មានភិក្ខុណា ឲ្យលេះលើសជាងព្រះសារីបុត្តឡើយ, តាំងម្ល៉ឹងហើយលោកនៅតែមិនកាន់ខ្លួនបួនកាលទៅធម្មសាកច្ឆានឹងភិក្ខុនេះ បួនកាលនឹងភិក្ខុនោះ, គេបុច្ឆាមកលោកក៏មាន លោកបុច្ឆាទៅគេវិញក៏មាន ជាធម្មតា, បើប្រសិនណាជាន់យើងឥឡូវ ប្រហែលជាក្រញូវ

www.budinst.gov.kh www.elibraryofcambodia.org

នឹងព្រះសារីបុត្តយ៉ាងធំថា លោក ប្រើប្ញកមិនហ៊ាំសមជា អគ្គសាវកធំ ឧត្តមដោយបញ្ញា បេះតែដើរទៅធម្មសាកច្ឆា នឹងគេឲ្យតែរាំសាប ។

ហេតុនេះ គួរតែយើងដែលមានបំណោះទន់ដុនដាប ត្រូវតែយកព្រះសារីបុត្តជាទិដ្ឋានុគតិ គឺគួរយ៉ាង, កុំមាន មានះក្អេងក្អាងត្រង់ប្រៃ ឬសាបនោះឡើយ គួរហើយតែខំ សិក្សាខាត់ខ្លួនសន្តានឲ្យបានបរិសុទ្ធ ផុតពីកិលេសាសវៈ អវិជ្ជា តណ្ហា ផ្សិតសត្វលោកក្នុងត្រៃភព ដែលជាប់ដោយ តណ្ហា ទោះបីបានទៅកើតជាទេវតាឥន្ទ្រព្រហ្មធំជាងគេ ក៏ គង់តែវេមករើកម្មត្រាំក្នុងកាម សោយសុខ សោយទុក្ខ ប្រឡូកប្រប្ញកប្រែបល់គ្នា រាប់ផងរាប់គ្រាពុំមានអស់, គួរតែ

សាធុសប្បុរសឲ្យស្គាល់ថា សត្វលោកឯណាដែលប្រកប ដោយខន្ធ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ក៏ពុំមានៈ ផុតអំពីអនិច្ចំ ទុក្ខំ អនត្តា គឺមិនទៀង ជាទុក្ខ អត្តខ្លួនៈ រកត្រង់ណាឲ្យខ្ជាប់ខ្ជួនឋិតថេរគ្មាន ដូចមានព្រះបរមពុទ្ធ-ដីក សម្តេចព្រះបរមលោកនាថ ទ្រង់ត្រាស់ថា សព្វេ សង្ខារា អនិច្ចា សព្វេ ធម្មា អនត្តា ប្រែថា សង្ខារទាំងឡាយទាំងពួងមិនទៀង ធម៌ទាំងឡាយទាំងពួង អត្តអាត្មា ។

អត្ថាធិប្បាយថា សង្ខារ គឺសេចក្តីតាក់តែងទាំងឡាយ ឥតវិញ្ញាណក៏មាន ដែលមានវិញ្ញាណក៏មាន ដែលមាន វិញ្ញាណនោះសោត ទោះបីមានកំណត់ទៅជាតិឯមុខក្តី ឬ គ្មានក្តី ក៏សឹងតែមិនទៀង, ធម៌ទាំងឡាយ គឺរូបធម៌ នាម-

www.budinst.gov.kh www.elibraryofcambodia.org

ធម៌ ដែលមានបច្ច័យប្រជុំតែងតែទៅជាតិឯមុខក្តី បុគ្គលក្តី ក៏សឹងតែអគ្គីអត្តា បើពោលឲ្យងាយយល់ គឺថា ព្រះវិ-ណាស្រពទាំងឡាយ ព្រះហឫទ័យលោក សុទ្ធតែវិសង្ខារ គឺឥតសង្ខារតាក់តែងទៅទៀតទេ, ធម៌ដែលលោកទ្រទ្រង់សោត ក៏ឥតរេទៅប្រជុំផ្តុំជាកាយឯណាដែរ ក៏ប៉ុន្តែ ខន្ធរបស់លោកដែលជាលោកិយ ក៏សឹងតែជាអនិច្ចំ ជាអនត្តា បានជាសម្តេចព្រះលោកុត្តមាចារ្យ ជាម្ចាស់ ទ្រង់ត្រាស់ប្រដៅថា កុំឲ្យកល័យបញ្ចក្ខន្ធ ដ្បិតខន្ធនេះនាំឲ្យរំពល់រវល់ណាស់ បើថា ខ្លះអាហារគ្មានបរិភោគ ក៏សឹងដាក់ទៅដោយអស្សុជល ទល់ទុក្ខពន់ប្រមាណ ប្រះព្រាណក្ស័យជីវិតក៏មាន ក៏ព្រោះគ្មានបញ្ញាប្រហារ ទូរហេតុឲ្យដាច់ស្រឡះ ។

www.budinst.gov.kh www.elibraryofcambodia.org

វីសម្តេចព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ជ្រាបច្បាស់នូវហេតុនិងផល ទីកើត ទីរលត់គ្រប់ប្រការ ដែលទ្រង់ឲ្យពុទ្ធបរិស័ទ្យ ហាត់ពិចារណា នូវបញ្ចអភិណ្ហប្បច្ចវេក្ខណៈមានជរាជាដើម ដើម្បីឲ្យបន្ទោបង់ចិត្តដែលស្រវឹងក្នុងវ័យថា ខ្លួនពុំទាន់ជរា ដែលទ្រង់មានព្រះពុទ្ធដីកាឲ្យពិចារណានូវព្យាធិ ដើម្បីឲ្យបន្ទោបង់ចិត្ត ដែលស្រវឹងនឹងអត្តភាពនៃខ្លួនថា នៅពុំទាន់មានរោគរឿ, ដែលទ្រង់ឲ្យពិចារណានូវសេចក្តីមរណៈ ដើម្បីឲ្យបន្ទោបង់ចិត្តដែលស្រវឹងថា ខ្លួនមិនទាន់ដល់ថ្នាក់ក្ស័យជីវិត, ដែលទ្រង់ឲ្យគិតនូវសេចក្តីប្រាសព្រាត់ ដើម្បីឲ្យបន្ទោបង់ចិត្តដែលស្រវឹងបដិពទ្ធនឹងវត្ថុដែលជាទីគាប់ចិត្ត, ដែលទ្រង់ឲ្យគិតពិចារណានូវកម្ម ដើម្បីឲ្យបន្ទោបង់ចិត្តដែលស្រវឹង នឹងសេចក្តីទុច្ចរិត ក្នុងត្រៃទ្វារ

www.budinst.gov.kh www.elibraryofcambodia.org

ទាំង ៣ ។

ឯសេចក្ដីចាស់ ឈឺ ស្លាប់ ព្រាត់ប្រាសនិកាសនេះ មនុស្សទាំងប្រុសស្រ្តីសឹងតែដឹងគ្រប់គ្នា តែគ្មានវិចារណ-បញ្ញា រមែងប្រកបដោយតណ្ហា វង្វេងទៅតាមការដែលលោកសម្មតិ ឥតតម្រិះឲ្យស្គាល់ហេតុនូវផល, គឺឯសេចក្ដីចាស់ ឈឺ ស្លាប់ ព្រាត់ប្រាស ទុក្ខសោក ទាំងពួងនេះ គឺផលមកអំពីមាន អវិជ្ជា តណ្ហា ឧបាទាន កម្ម ទាំង ៤ នេះជាមេហេតុ, បើនឹងធ្វើឲ្យហេតុរលត់ លុះតែពត់ចិត្តប្រព្រឹត្តឲ្យត្រង់ផ្លូវសម្មាបដិបត្តិ ទើបបាត់ជា ដល់ទីបរមសុខដ៏ប្រសើរពោលគឺព្រះនិព្វានដែលផុតហេតុ គ្មានជាតិ ជរា ព្យាធិ មរណៈ ភ័យកិត ដូចដាលដល់ជិត ។

សម្ដែងកន្លងបញ្ចអភិណ្ហបច្ចវេក្ខណៈ ជាសន្និតកថា

# បញ្ជីសៀវភៅដែលពុទ្ធសាសនបណ្ឌិត្យ
## បោះពុម្ពផ្សាយ

| | |
|---|---|
| កច្ចាយនូបត្ថម្ភកៈទី ១ . . . . . មួយសៀវភៅថ្លៃ | ២២៛០០ |
| — ២ . . . . . . . | ២៦៛០០ |
| កង្ខាវិតរណីទី ១ . . . . . . . . | ១២៛០០ |
| — ២ . . . . . . . . | ១០៛០០ |
| — ៣ . . . . . . . . | ១១៛០០ |
| — ៤ . . . . . . . . | ១២៛០០ |
| កាលាមសូត្រ . . . . . . . | ៣៛០០ |
| កុម្ភជាតក . . . . . . . . | ៣៛០០ |
| ក្រុងសុភមិត្រ . . . . . . . | ១២៛០០ |
| គតិលោកទី ១ ដល់ទី១០ . . . . មួយភោសៀវថ្លៃ | ៤៛០០ |
| គម្ពីរ វជិរសារៈ . . . . . . . | ១០៛៥០ |
| គិរិមានន្ទសូត្រ . . . . . . . | ៤៛០០ |
| គហិបតិបត្តិ . . . . . . . | ១០៛០០ |

www.budinst.gov.kh www.elibraryofcambodia.org

| | |
|---|---|
| គាថាសមថកម្មដ្ឋាន | ៤រ០០ |
| ចម្រៀងជាតិនិយម | ៨រ០០ |
| ច្បាប់ល្បើកថ្មី | ៤រ០០ |
| ច្បាប់ផ្សេង ៗ ទី ១ | ៤រ០០ |
| – ២ | ៤រ០០ |
| – ៣ | ៤រ០០ |
| ច្បាប់ស្រី ព្រះអង្គឌួង | ១០រ០០ |
| ច្បាប់សុភាសិត | ៣រ៥០ |
| ជយវរ្ម័នទីពីរអក្សរខ្មែរ | ៥រ០០ |
| – អក្សរបារាំង | ១០រ០០ |
| ញាណកថា | ៣រ០០ |
| ទសបារមីកថា | ៦រ០០ |
| ទានកថា | ៦រ០០ |
| ទំនៀមការផ្ទាល់ខ្លួន | ៧រ០០ |
| ទុំទាវ | ១០រ០០ |
| ធម្មប្រទីប | ១០រ០០ |
| ធម្មបទដ្ឋកថាទី ១ | ២៤រ០០ |

www.budinst.gov.kh www.elibraryofcambodia.org

| | | |
|---|---|---|
| ធម្មបទដ្ឋកថាទី | ២ | ១៨រ០០ |
| — | ៣ | ២៤រ០០ |
| — | ៤ | ២៤រ០០ |
| — | ៥ | ១៦រ០០ |
| — | ៦ | ២០រ០០ |
| — | ៧ | ១៩រ០០ |
| — | ៨ | ១៩រ០០ |
| ទាតោបមាទិកថា | | ១រ៥០ |
| ទាទាជាតក | | ១៤រ០០ |
| បក្ខគណនាវិធី | | ៣រ០០ |
| បញ្ចអភិណ្ហបច្ចវេក្ខណៈ | | ៥រ០០ |
| បញ្ញាសជាតកភាគទី | ១ | ១៦រ០០ |
| — | ២ | ១២រ០០ |
| — | ៣ | ១២រ០០ |
| — | ៤ | ១២រ០០ |
| — | ៥ | ១៧រ០០ |


www.budinst.gov.kh www.elibraryofcambodia.org

| | | |
|---|---|---|
| បញ្ញាសជាតកសម្រាយទី | ១ | ៦៤៛០០ |
| — | ២ | ១៧៛០០ |
| — | ៣ | ១៧៛០៦ |
| — | ៤ | ១៩៛០០ |
| — | ៥ | ២០៛០០ |
| បទានុក្រម រាមកេរ្តិ៍ | | ៥៛០០ |
| បព្វជ្ជាខន្ធកសង្ខេប | | ៩៛០០ |
| បាតិមោក្ខសង្ខេប | | ៨៛០០ |
| បាយាសិរាជញ្ញសូត្រ | | ២៛៥០ |
| ប្រជុំរឿងព្រេងទី ១ | | ២២៛០០ |
| — | ២ | ២៣៛០០ |
| — | ៣ | ១៨៛០០ |
| — | ៤ | ១៨៛០០ |
| — | ៥ | ២៥៛០០ |
| — | ៦ | ២៤៛០០ |
| ប្រវត្តិមហាពោធិព្រឹក្ស | | ២៛០០ |

| | |
|---|---|
| ប្រស្នាវិនយបិដកសង្ខេប . . . . . . | ២៩៛០០ |
| គន្ធីអាស៊ីទ្វីប . . . . . . . | ២៦៛០០ |
| ពាក្យកាព្យប្រដៅផងប្រុសស្រី . . . . . | ៣៛០០ |
| ពាក្យកាព្យពុទ្ធប្បវត្តិ . . . . . . | ៣៛០០ |
| ពិធីទាទសមាសអក្សរខ្មែរ ទី ១ . . . . . . | ១៨៛០០ |
| — ២ . . . . . . . | ១៧៛០០ |
| — ៣ . . . . . . . | ១៥៛០០ |
| ពុទ្ធមាមកវិធី . . . . . . . | ៩៛០០ |
| ពុទ្ធោវាទានុសាសនី . . . . . . | ៦៛០០ |
| ព្រហ្មចរិយកថា . . . . . . . | ១៥៛០០ |
| ព្រះបាទអសោក . . . . . . . | ១៦៛០០ |
| ព្រះត្រៃលក្ខណ៍ . . . . . . . | ៦៛០០ |
| ភាណវារបាលី . . . . . . . | ៦២៛០០ |
| ភិក្ខុប្បាតិមោក្ខបាលី . . . . . . | ៩៛០០ |
| ភោគកុលកុមារ . . . . . . . | ២០៛០០ |
| មគ្គុទ្ទេសក៍នគរទី ១ . . . . . . | ៨៛០០ |


www.budinst.gov.kh www.elibraryofcambodia.org

មគ្គុទ្ទេសក៍ផតរ ទី ២ . . . . . . . ២៨៛០០

មនោបុញ្ញកថា . . . . . . . ៣៛០០

មរណានុស្សតិកម្មដ្ឋាន . . . . . . . ៤៛០០

មហាវេស្សន្តរជាតក . . . . . . . ៤៥៛០០

មហាបុរិសលក្ខណៈ . . . . . . . ៣៛០០

មាតាបិតុឧបដ្ឋានកថា . . . . . . . ៦៛០០

មាយើង . . . . . . . . ១០៛០០

មង្គលត្ថទីបនី ទី ១ . . . . . . . ៣០៛០០

— ២ . . . . . . . ៣៥៛០០

— ៣ . . . . . . . ៤៥៛៥០

— ៤ . . . . . . . ៣៥៛៥០

មិលិន្ទបញ្ហា ទី ១ . . . . . . . ២០៛០០

— ២ . . . . . . . ២០៛០០

រតនប្បភា . . . . . . . ៧៛០០

របាំប្រជាប្រិយខ្មែរ . . . . . . . ២៧៛០០

រាមកេរ្តិ៍ ទី ១ ដល់ ១០ និង ៧៤ ដល់ ៩០ មួយសៀវភៅ . ៤៛០០


www.budinst.gov.kh www.elibraryofcambodia.org

| | |
|---|---|
| រឿង មរណមាតា | ១៦រ០០ |
| — កាកី | ៩រ០០ |
| រឿង ទិព្វសង្វារទី ១ ដល់ ៥ មួយសៀវភៅ | ៣០រ០០ |
| — សព្វសិទ្ធិ | ១៤រ០០ |
| — ព្រះជិនវង្សទី ១ ដល់ ៤ មួយសៀវភៅ | ៣៣រ០០ |
| — ព្រះសុធន | ១៧រ០០ |
| — ហង្សយន្ត | ១៤រ០០ |
| - ពុទ្ធិសែន | ១៤រ០០ |
| — ស័ង្ខសិល្បជ័យ | ២៨រ០០ |
| — សុបិនកុមារ | ៧រ០០ |
| — ខ្យងស័ង្ខ | ១៦រ០០ |
| — ស្រទបចេក | ២៥រ០០ |
| — ធនញ្ជ័យ | ៩០រ០០ |
| សៀវភៅក្បួនត្បាញហូលហោបិន | ៣រ០០ |
| ល្បែងប្រជាប្រិយខ្មែរ | ២៦រ០០ |

www.budinst.gov.kh www.elibraryofcambodia.org

| | |
|---|---|
| លោកនយប្បករណ៍ទី ១ | ២៤រ០០ |
| — ២ | ២៣រ០០ |
| លក្ខន្តិកៈកសាងវត្ត | ៩រ០០ |
| វចនានុក្រមខ្មែរទី ១ | ២៨០រ០០ |
| — ២ | ៣០០រ០០ |
| វិសាលសូត្រ | ៣រ០០ |
| វិជ្ជាបរណកថា | ៦រ០០ |
| វិជ្ជាប្រាំបីប្រការ | ២០រ០០ |
| វិសុទ្ធិមគ្គជាលីទី ១ | ៥២រ០០ |
| — ២ | ៥០រ០០ |
| — ៣ | ៥០រ០០ |
| វេយ្យាករណ៍សំស្ក្រឹត | ២៨រ០០ |
| សត្តបរិត្ត - ទ្វាទសបរិត្ត | ១៧រ០០ |
| សតិបដ្ឋានសូត្រ | ៩រ០០ |
| សប្បុរិសធម៌ | ៣រ០០ |

www.budinst.gov.kh www.elibraryofcambodia.org

សមន្តប្បាសាទិកាទី ១ . . . . . . . . ៣៥១០០
— ២ . . . . . . . . ៥០១០០
— ៣ . . . . . . . . ៥៧១០០
— ៤ . . . . . . . ៦០១០០
សម្ពន្ធមាលា . . . . . . . . ៤០១០០
សារទេសនា . . . . . . . . ២១០០
សាមរណាវិន័យ . . . . . . . . ៧១០០
សិលាចារឹកនគរវត្ត . . . . . . . ១៥១០០
សីមាវិនិច្ឆ័យ . . . . . . . . ៣១០០
សីលនិទ្ទេស . . . . . . . . ១៦១០០
សិង្គាលោវាទសូត្រ . . . . . . . ៦១០០
សុភាសិតច្បាប់កសិនី . . . . . . . ៣១០០
សុភាសិតច្បាប់ស្រី . . . . . . . ៦១០០
សុត្តពិសុត្រ . . . . . . . . ៤១០០
សុវណ្ណជាតក . . . . . . . . ១៥១០០
សុភទោសកថា . . . . . . . . ២១០០


www.budinst.gov.kh www.elibraryofcambodia.org

| | |
|---|---|
| សុរិយាត្រឡើងស័ក | ៣រ០០ |
| សោកសោមបណ្ឌិត | ៤រ០០ |
| សេចក្តីរំលឹកដាស់តឿន | ៣រ០០ |
| សំដែងអំពីព្រះនិព្វាន | ៩រ០០ |
| សំវេងនីយធម៌ | ៣រ០០ |
| អក្ខទោសកថា | ៣រ០០ |
| អត្ថាធុសាសនី | ៦រ០០ |
| អនត្តលក្ខណសូត្រ | ២រ០០ |
| អនុមោទនាវិធី | ៨រ០០ |
| អនុត្តរិយវិសូត្រ | ១រ០០ |
| អភិនវភាសិត | ៣រ០០ |
| អភិធម្មត្ថសង្គហ សម្រាយ | ២៧រ០០ |
| — បាលី | ១០រ០០ |
| អរិយសច្ចកថា | ១០រ០០ |
| អវិសាទកិច្ច | ១០រ០០ |
| អំពីព្រះពុទ្ធសាសនាអក្សរខ្មែរ | ៥១រ០០ |
| — អក្សរបារាំង | ៥០រ០០ |

www.budinst.gov.kh www.elibraryofcambodia.org

| | | |
|---|---|---|
| អាឡវិកសូត្រ | . . . . . . . . | ៦រ០០ |
| ឯកសហស្រភត្រី ទី ១ | . . . . . . | ៥រ០០ |
| — ២ | . . . . . . | ៤រ០០ |
| — ៣ | . . . . . . | ៤រ០០ |
| — ៤ | . . . . . . | ៤រ០០ |
| — ៥ | . . . . . . | ៥រ០០ |
| — ៦ | . . . . . . | ៤រ០០ |
| — ៧ | . . . . . . | ៥រ០០ |
| — ៨ | . . . . . . | ៥រ០០ |
| — ៩ | . . . . . . | ៤រ០០ |
| — ១០ | . . . . . . | ៥រ០០ |
| — ១១ | . . . . . . | ៥រ០០ |
| — ១២ | . . . . . . | ៥រ០០ |
| — ១៣ | . . . . . . | ៥រ០០ |
| — ១៤ | . . . . . . | ៥រ០០ |


www.budinst.gov.kh www.elibraryofcambodia.org

| | |
|---|---|
| ឯកសហស្រភត្រី ទី ១៥ | ១០៖០០ |
| — ១៦ | ៦៖៤០ |
| — ១៧ | ៥៖៥០ |
| — ១៨ | ៥៖០០ |
| — ១៩ | ៧៖៤០ |
| — ២០ | ៩៖០០ |
| — ២១ | ៩៖០០ |
| — ២២ | ៩៖០០ |
| — ២៣ | ៩៖០០ |
| — ២៤ | ៩៖០០ |
| — ២៥ | ៦៖០០ |
| — ២៦ | ៧៖០០ |
| — ២៧ | ៧៖០០ |
| — ២៨ | ៩៖០០ |
| — ២៩ | ៧៖០០ |
| — ៣០ | ៧៖០០ |


www.budinst.gov.kh www.elibraryofcambodia.org

ឯកសហស្រភាត្រី ទី ៣០ ដល់ ៣៧ មួយខ្សែ . . . ៧រ០០
— ៣៨ — ៥១ — . . . ៦រ០០
មហោសថជាតក . . . . . . . ៣៥រ០០
ប្រវត្តិពុទ្ធសាសនា . . . . . . . ២៣រ០០
ទ្វេភិទប្បាតិមោក្ខ . . . . . . . ២៦រ០០
អំពីប្រាសាទខ្លះនៅអង្គរ . . . . . ១៣រ០០
ពិធីប្រចាំដប់ពីរខែ . . . . . . ២០រ០០
វចនាខ្មែរ-អក្សរបារាំង . . . . . ៧០រ០០
ពិធីទ្វាទសមាស-អក្សរបារាំង . . . . ៣០រ០០
ពិធីក្នុងគ្រួសារខ្មែរ-អក្សរបារាំង . . . . ៤០រ០០
ចម្រៀងសន្តិភាព អក្សរបារាំង . . . . . ២៥រ០០
ដើមកំណើតអង្គរ — . . . . . . ២៣រ០០
អធិប្បាយចតុបារិសុទ្ធិសីល . . . . . . ៩រ៣០
អធិប្បាយប្រជុំកងធម៌ ទី ១ . . . . . . ១៥រ០០
— ២ . . . . . ១៦រ០០
អនាបត្តិនិទ្ទេស . . . . . . . ៧រ០០

www.budinst.gov.kh www.elibraryofcambodia.org

| | |
|---|---|
| ពុទ្ធប្បវត្តិ ទូរេនិទាន . . . . . . . | ៧រ០០ |
| ពុទ្ធប្បវត្តិ អវិទូរេនិទាន . . . . . . | ៨រ០០ |
| ចតុប្បារិសុទ្ធិសីល . . . . . . . | ៦រ០០ |
| ប្រជុំកងធម៌ថ្នាក់ត្រី . . . . . . . | ៩រ០០ |
| — ទោ . . . . . . . | ៨រ០០ |
| សាសនសុភាសិតទី ១ . . . . . . | ១៣រ០០ |
| — ២ . . . . . . | ៦រ០០ |
| — ៣ . . . . . . | ៨រ០០ |
| អធិប្បាយសាសនសុភាសិត . . . . . . | ៦រ០០ |
| វិនយបឋមកឋិនបរិហារ . . . . . . | ៣រ៥០ |
| វិនយសង្ឃកម្មកថាទី ១ . . . . . . | ១៦រ៥០ |
| — ២ . . . . . . | ១៨រ៥០ |


www.budinst.gov.kh www.elibraryofcambodia.org

PHNOM PENH

www.budinst.gov.kh www.elibraryofcambodia.org